**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៦៤ សហវ.ក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាការិយាល័យនៃ នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានបែបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបង្កើត និងដាក់ឲ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ដាការិយាល័យ នៃនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្ដាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន កិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនពីរ (០២) ដូចខាងក្រោម ៖

- ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ
- ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ

បណ្ដាការិយាល័យនីមួយៗរបស់នាយកដ្ឋាន កិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- សហការស្រាវជ្រាវ និងផ្ដល់យោបល់ ពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ
- ទទួលបន្ទុកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ និងការធ្វើវិសោធនកម្ម ឬការកែសម្រួលបទប្បញ្ញត្តិគយ ✓

~/.

- ទទួលបន្ទុកពិនិត្យ និងចូលរួមពិនិត្យសំណើសុំបង្កើតកណ្តាគារគយមានដែនកំណត់ តំបន់រួចពន្ធ និងបណ្តាអាជីវកម្មដ្ឋានប្រហាក់ប្រហែល និងចាត់ចែង គ្រប់គ្រង ត្រួតពិនិត្យ ទីកន្លែង និងសេវាកម្មទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងកិច្ចសន្យាជាធរមាននានា
- ទទួលបន្ទុកគ្រប់គ្រងកំណត់ហេតុបទល្មើសគយ និងមានការកិច្ចសម្រុះសម្រួលបទល្មើសគយ និងវិវាទផ្សេងទៀត ដោយផ្តល់យោបល់សម្រាប់បម្រើឲ្យការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានា ដាក់ជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ពិនិត្យ និងសម្រេច ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- តម្កល់ឯកសារ និងបទប្បញ្ញត្តិច្បាប់ជាធរមាននានា និងណែនាំដល់គ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អំពីរបៀបគ្រប់គ្រង ថែទាំឯកសារទាំងនេះ
- ទទួលពិនិត្យ និងវាយតម្លៃនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជន និងបុគ្គលពាក់ព័ន្ធនានា ក្នុងនាមជាអង្គភាពទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងគោលដៅរក្សាតុល្យភាពរវាងប្រសិទ្ធភាព នៃការអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ ត្រូវអនុវត្តតាមបញ្ញត្តិប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ និងមានមុខងារ និងការកិច្ចបន្ថែមដូចតទៅ ៖

- ទទួលបន្ទុកជាអង្គភាពគ្រប់គ្រងជើងសារគយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

.../

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន៖</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ